**ព័ត៌មានអំពីសិទ្ធិតាមផ្លូវច្បាប់ដែលមានសំរាប់ជនអន្តោប្រវេសន៍រងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហរដ្ឋអាមេរិក និងព័ត៌មានអំពីការធ្វើអន្តោប្រវេសន៍តាមរយៈទិដ្ឋាការរៀបការ។**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ IMBRA ទាមទារអោយរដ្ឋាភិបាលសហរដ្ឋអាមេរិកផ្តល់ជូនដល់គូដណ្តឹង និងប្តី / ប្រពន្ធសញ្ជាតិបរទេស ដែលធ្វើអន្តោប្រវេសន៍មករស់នៅសហរដ្ឋអាមេរិកនូវព័ត៌មានអំពីសិទ្ធិស្របច្បាប់របស់ពួកគេ ព្រមទាំងប្រវត្តិបទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សាក្នុងគ្រួសាររបស់ប្តី / ប្រពន្ធ / គូដណ្តឹងសញ្ជាតិអាមេរិករបស់ពួកគេ។

**តើអំពើហិង្សាក្នុងគ្រួសារជាអ្វី ?**

អំពើហិង្សាក្នុងគ្រួសារ គឺជាទំរង់ឥរិយាបថ ដែលដៃគូស្នេហា ឬប្តី/ប្រពន្ធ គំរាមកំហែងឬធ្វើបាបដៃគូម្ខាងទៀត។ ការធ្វើបាបអាចជាការបង្កគ្រោះថ្នាក់ដល់រូបរាងកាយ ការបង្ខំក្នុងការរួមភេទ ការធ្វើអោយប៉ះពាល់ដល់សតិអារម្មណ៍ (ដែលរួមមាន ការដាក់អោយនៅដាច់ពីគេ ឬការបន្ទាបបន្ថោក) ការគំរាមកំហែងដែលទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចនិងអន្តោប្រវេសន៍។ ទោះជាករណីនៃអំពើហិង្សាក្នុងគ្រួសារដែលបានកត់ត្រាភាគច្រើនគឺការប្រព្រឹត្តិរបស់បុរសមកលើស្ត្រីឬកុមារក៏ដោយ បុរសក៏អាចជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារដែរ។

អំពើហិង្សាក្នុងគ្រួសាររួមមាន ហិង្សាផ្លូវភេទ ការធ្វើបាបកុមារ និង បទល្មើសហិង្សាផ្សេងទៀត។ ហិង្សាផ្លូវភេទ គឺសកម្មភាពផ្លូវភេទដែលអ្នកមិនយល់ព្រម។

មិនថាឋិតក្នុងកាលៈទេសៈណាក៏ដោយ អំពើហិង្សាក្នុងគ្រួសារ ហិង្សាផ្លូវភេទ ការធ្វើបាបកុមារ គឺជាទង្វើខុសច្បាប់នៅសហរដ្ឋ-អាមេរិក។ ក្រោមច្បាប់សហរដ្ឋអាមេរិក ជនរងគ្រោះគ្រប់រូបនៅក្នុងសហរដ្ឋ-អាមេរិក ទោះស្ថានភាពអន្តោប្រវេសន៍ ឬ សញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយ  ក៏ពួកគេអាចស្វែងរកជំនួយបានដែរ ដោយទាក់ទងប៉ូលីសដើម្បីសុំជំនួយ ឬ ដើម្បីស្នើសុំដីកាបង្គាប់អោយមានការការពារ។

លេខទូរស័ព្ទក្នុងសហរដ្ឋអាមេរិក ឬលេខទូរស័ព្ទសំរាប់រឿងបន្ទាន់ដែលមានខាងក្រោម មានអ្នកទទួលដែលមានការបណ្តុះបណ្តាល និងអាចបកប្រែ ដើម្បីជួយដល់ជនរងគ្រោះ ២៤ ម៉ោងក្នុងមួយថ្ងៃ ដោយមិនគិតប្រាក់។

**ទំនាក់ទំនងអំពីអំពើហិង្សាក្នុងគ្រួសារ**

លេខទូរស័ព្ទ: 1-800-799-SAFE (1-800-799-7233)
1-800-787-3224 (TTY)
គេហទំព័រ: www.ndvh.org

**ទំនាក់ទំនងអំពើហិង្សាផ្លូវភេទ ការចាប់រំលោភ ការធ្វើបាប និង ទំនាក់ទំនាក់ផ្លូវភេទរវាងសាច់ញាតិ (RAINN)**

លេខទូរស័ព្ទ: 1-800-656-HOPE (1-800-656-4673)
គេហទំព័រ: www.rainn.org

**មជ្ឈមណ្ឌលជាតិទទួលបន្ទុកការបាត់ខ្លួន និងអំពើកេង-ប្រវ័ញ្ចលើកុមារ**

លេខទូរស័ព្ទ: 1-800-THE-CALL (1-800-843-5678)
គេហទំព័រ: www.missingkids.com

**មជ្ឈមណ្ឌលជាតិទទួលបន្ទុកជនរងគ្រោះ ដោយសារបទល្មើស**

លេខទូរស័ព្ទ: 1-800-FYI-CALL (1-800-394-2255)
1-800-211-7996 (TTY)

សូមអានព័ត៌មានលំអិតនៅទំព័របន្ទាប់។

**ព័ត៌មានអំពីសិទ្ធិតាមផ្លូវច្បាប់ដែលមានសំរាប់ជនអន្តោប្រវេសន៍រងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហរដ្ឋអាមេរិក និងព័ត៌មានអំពីការធ្វើអន្តោប្រវេសន៍តាមរយៈទិដ្ឋាការរៀបការ ។**

**គោលបំណង៖**

ជនអន្តោប្រវេសន៍គឺជាជនដែលងាយរងគ្រោះពីព្រោះពួកគេភាគច្រើនមិនចេះនិយាយភាសាអង់គ្លេសព្រមទាំងប្រហែលជាមិនយល់ច្បាប់សហរដ្ឋអាមេរិក និងជារឿយៗរស់នៅឆ្ងាយពីគ្រួសារ និងមិត្តភក្តិ។ ដោយសារមូលហេតុនេះ  ជនអន្តោប្រវេសន៍ភ័យខ្លាចមិនហ៊ានរាយការណ៍អំពីអំពើហិង្សាទៅដល់ប៉ូលីស ឬស្វែងរកជំនួយផ្សេងៗ។  ការភ័យខ្លាចទាំងនេះ បណ្តាលអោយជនអន្តោប្រវេសន៍ភាគច្រើនទ្រាំរស់នៅក្នុងជីវិតគ្រួសារដែលប្រកបដោយអំពើហិង្សា ។

ក្រដាសព័ត៌មាននេះនឹងពន្យល់អំពីអំពើហិង្សាក្នុងគ្រួសារ និងផ្តល់ព័ត៌មានអំពីសិទ្ធិស្របច្បាប់របស់អ្នកពេលអ្នករស់នៅក្នុងសហរដ្ឋ-អាមេរិក។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ IMBRA ទាមទារអោយរដ្ឋា-ភិបាលសហរដ្ឋអាមេរិក ផ្តល់ជូនដល់គូដណ្តឹង និង ប្តី / ប្រពន្ធសញ្ជាតិបរទេសដែលធ្វើអន្តោប្រវេសន៍មករស់នៅសហរដ្ឋអាមេរិកនូវព័ត៌មានអំពីសិទ្ធិស្របច្បាប់របស់ពួកគេព្រមទាំងប្រវត្តិបទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សាក្នុងគ្រួសាររបស់ ប្តី / ប្រពន្ធ / គូដណ្តឹងសញ្ជាតិអាមេរិករបស់ពួកគេ។ គោលដៅមួយរបស់ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ IMBRA គឺផ្តល់ព័ត៌មានត្រឹមត្រូវពិតប្រាកដទៅដល់គូដណ្តឹង និងប្តី / ប្រពន្ធជនបរទេស ដែលធ្វើអន្តោប្រវេសន៍អំពីដំណើរការអន្តោប្រវេសន៍ និង ការទទួលជំនួយ ប្រសិនបើទំនាក់ទំនងរបស់ពួកគេមានបញ្ហា ។

## តើអំពើហិង្សាក្នុងគ្រួសារជាអ្វី?

អំពើហិង្សាក្នុងគ្រួសារ គឺជាទំរង់ឥរិយាបថ ដែលដៃគូស្នេហា ឬ ប្តី/ប្រពន្ធ គំរាមកំហែងឬធ្វើបាបដៃគូម្ខាងទៀត។ ការធ្វើបាបអាចជាការបង្កគ្រោះថ្នាក់ដល់រូបរាងកាយ ការបង្ខំក្នុងការរួមភេទ ការធ្វើអោយប៉ះពាល់ដល់សតិអារម្មណ៍ (ដែលរួមមាន ការដាក់អោយនៅដាច់ពីគេ ឬការបន្ទាបបន្ថោក) ការគំរាមកំហែងដែលទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ច និងអន្តោប្រវេសន៍។ ទោះជាករណីនៃអំពើហិង្សាក្នុងគ្រួសារដែលបានកត់ត្រាភាគច្រើន គឺការប្រព្រឹត្តិរបស់បុរសមកលើស្ត្រី ឬ កុមារក៏ដោយ បុរសក៏អាចជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារដែរ។

អំពើហិង្សាក្នុងគ្រួសាររួមមាន ហិង្សាផ្លូវភេទ ការធ្វើបាបកុមារ និងបទល្មើសហិង្សាផ្សេងទៀត។ ហិង្សាផ្លូវភេទ គឺសកម្មភាពផ្លូវភេទ ដែលអ្នកមិនយល់ព្រម ទោះបីជាមួយ ប្តី / ប្រពន្ធអ្នកក៏ដោយ ហើយអំពើនេះអាចប្រព្រឹត្តិដោយអ្នកណាម្នាក់ផ្សេងទៀតផងដែរ។ អំពើធ្វើបាបកុមាររួមមាន ការធ្វើបាបរូបរាងកាយ (របួសស្នាមដែលកើតឡើងមិនមែនជាឧបត្តិហេតុ រួមទាំងការដាក់ទណ្ឌកម្មហួសហេតុពេក) កង្វះការយកចិត្តទុកដាក់ផ្នែករូបរាងកាយ (ខកខានមិនបានផ្តល់អាហារ ជំរក ឬ ការថែទាំផ្នែកសុខាភិបាល) ការធ្វើបាបផ្លូវភេទ និងផ្លូវចិត្ត (ការគំរាម-កំហែងឈប់ផ្តល់សេចក្តីស្រលាញ់ និងការទំនុកបំរុង)។

មិនថាបិតក្នុងកាលៈទេសៈណាក៏ដោយ អំពើហិង្សាក្នុងគ្រួសារ ហិង្សាផ្លូវភេទ ការធ្វើបាបកុមារ គឺជាទង្វើខុសច្បាប់នៅសហរដ្ឋ-អាមេរិក។ ជនគ្រប់រូបត្រូវបានជានានូវការការពារដោយច្បាប់អោយផុតពីការធ្វើបាបផ្សេងៗដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ អាយុ ឬ ស្ថានភាពអន្តោប្រវេសន៍។ ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ទោះស្ថានភាពអន្តោប្រវេសន៍ ឬ សញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយ ក៏ពួកគេអាចស្វែងរកជំនួយបានដែរ។ ជនអន្តោប្រវេសន៍រងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ អាចមានសិទ្ធិក្នុងការទទួលការការពារផ្នែកអន្តោប្រវេសន៍ ។

លោកអ្នកមិនមែននៅឯកោតែម្នាក់ឯងនោះទេ ប្រសិនបើអ្នកកំពុងជួបប្រទះអំពើហិង្សាក្នុងគ្រួសារ។ ក្រដាសព័ត៌មាននេះមានបំណងជួយអ្នកអោយយល់ច្បាប់សហរដ្ឋអាមេរិក និងអោយដឹងថាតើអ្នកអាចរកជំនួយបានយ៉ាងដូចម្តេចពេលដែលអ្នកត្រូវការ។

## តើសិទ្ធិស្របច្បាប់ដែលមានសំរាប់ជនអន្តោប្រវេសន៍រងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហរដ្ឋអាមេរិកមានអ្វីខ្លះ?

ជនគ្រប់រូបនៅក្នុងសហរដ្ឋអាមេរិកទោះស្ថានភាពអន្តោប្រវេសន៍ ឬសញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយ ក៏ពួកគេត្រូវបានជានានូវការការពារជាមូលដ្ឋាន ក្រោមច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្ម-ទណ្ឌ។ ច្បាប់ស្តីពីគ្រួសារផ្តល់ជូនអ្នកនូវៈ

- សិទ្ធិក្នុងការទទួលដីការបង្គាប់អោយមានការការពារដល់អ្នក ព្រមទាំងកូន។
- សិទ្ធិទទួលការរស់នៅបែកគ្នា ឬលែងលះគ្នាស្របច្បាប់ ដោយមិនបាច់ទទួលការយល់ព្រមពីប្តី / ប្រពន្ធរបស់អ្នក។
- សិទ្ធិក្នុងការទទួលចំណែកនៃទ្រព្យសម្បត្តិរួមមួយចំនួនដែលកើតក្នុងជីវិតអាពាហ៍ពិពាហ៍។ ក្នុងករណីលែងលះ តុលាការនឹងបែងចែកទ្រព្យសម្បត្តិទាំងអស់ដែលអ្នកមានរួមគ្នា។
- សិទ្ធិក្នុងការគ្រប់គ្រងកូន និងទទួលការផ្គត់ផ្គង់ផ្នែកហិរញ្ញ-វត្ថុ។ ឪពុកម្តាយរបស់កូនក្រោមអាយុ ២១ឆ្នាំ ជាធម្មតាត្រូវបានទាមទារអោយផ្តល់របបឧបត្ថម្ភដល់កូន ទោះបីកូននោះមិនរស់នៅជាមួយពួកគេក៏ដោយ ។

ប្រឹក្សាជាមួយមេធាវីជំនាញផ្នែកគ្រួសារ ដែលធ្វើការជាមួយជនអន្តោប្រវេសន៍ ដើម្បីពិភាក្សាស្វែងរកថាតើច្បាប់គ្រួសារមួយណាពាក់ព័ន្ធ និងអាចជួយដល់រូបអ្នក។

ក្រោមច្បាប់សហរដ្ឋអាមេរិក ជនរងគ្រោះគ្រប់រូបនៅក្នុងសហរដ្ឋ-អាមេរិក ទោះស្ថានភាពអន្តោប្រវេសន៍ ឬសញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយ អាចទាក់ទងប៉ូលីសដើម្បីសុំជំនួយ ឬ ដើម្បីស្នើសុំដីការបង្គាប់អោយមានការការពារ។

សូមទូរស័ព្ទទៅ៩១១ដើម្បីសុំជំនួយពីនគរបាលប្រសិនបើអ្នកនិងកូនរបស់អ្នកជួបប្រទះបញ្ហា។ នគរបាលអាចចាប់ខ្លួនគូដណ្តឹង ប្តី/ប្រពន្ធ ដៃគូស្នេហា ឬជនណាម្នាក់ ប្រសិនបើប៉ូលីសជឿថាជននោះបានប្រព្រឹត្តិបទល្មើស។ អ្នកគួររាយការណ៍ដល់នគរបាលរាល់ការធ្វើបាបដែលបានប្រព្រឹត្តិមកលើអ្នក ទោះជារឿងនោះបានកើតឡើងនៅក្នុងអតីតកាលក៏ដោយ ហើយបង្ហាញពួកគេរាល់របួសស្នាមដែលកើតមាន។ ជនណាក៏ដោយទោះស្ថានភាពអន្តោ-ប្រវេសន៍ ឬសញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយអាចធ្វើការរាយ-ការណ៍អំពីបទល្មើសបានទាំងអស់ ។

ដូចគ្នានេះដែរ ប្រសិនបើអ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អ្នកអាចដាក់ពាក្យស្នើសុំទៅតុលាការអោយចេញដីការបញ្ជាអោយមានការការពារ។ ដីការបញ្ជាអោយមានការការពារឬអោយមានការបញ្ឈប់ដែលចេញដោយតុលាការ អាចហាមឃាត់អ្នកដែលធ្វើបាបអ្នក កុំអោយទូរស័ព្ទទាក់ទង ឬ មកជិតអ្នកក្នុង

គោលបំណងបង្គ្រោះថ្នាក់ដល់អ្នក កូនរបស់អ្នក ឬ សមាជិកណាម្នាក់ក្នុងគ្រួសារអ្នក។ ប្រសិនបើអ្នកដែលធ្វើបាបអ្នកបំពានដីការបញ្ជាអោយមានការការពារ អ្នកអាចទាក់ទងប៉ូលីសហើយប៉ូលីសអាចចាប់ខ្លួនអ្នកដែលធ្វើបាបអ្នក។ ពាក្យសុំដីការបញ្ជាអោយមានការការពារអាច រកបាននៅតុលាការការិយាល័យនគរបាលជំរកសំរាប់ស្ត្រី និងការិយាល័យសេវាកម្មច្បាប់ ។

ប្រសិនបើអ្នកដែលធ្វើបាបអ្នក ចោទប្រកាន់អ្នកថាបានប្រព្រឹត្តិល្មើស អ្នកមានសិទ្ធិជាមូលដ្ឋានដែលរួមមាន សិទ្ធិនិយាយជាមួយមេធាវី សិទ្ធិមិនឆ្លើយសំណួរពេលគ្មានមេធាវី និងសិទ្ធិក្នុងការនិយាយការពារខ្លួនទោះស្ថានភាពអន្តោប្រវេសន៍ ឬសញ្ជាតិរបស់អ្នកដូចម្តេចក៏ដោយ។ វាជារឿងសំខាន់ណាស់ក្នុងការពិភាក្សាជាមួយមេធាវីអន្តោប្រវេសន៍ និង មេធាវីព្រហ្មទណ្ឌ ។

## តើមានសេវាកម្មអ្វីខ្លះសំរាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទនៅក្នុងសហរដ្ឋអាមេរិក?

នៅក្នុងសហរដ្ឋអាមេរិក ជនរងគ្រោះទាំងអស់ ទោះស្ថានភាពអន្តោប្រវេសន៍ឬសញ្ជាតិរបស់ពួកគេដូចម្តេចក៏ដោយ អាចទទួលបានជំនួយដែលរួមមានការប្រឹក្សា អ្នកបកប្រែ កន្លែងស្នាក់នៅបន្ទាន់ ព្រមទាំងជំនួយផ្នែកប្រាក់កាសពីរដ្ឋាភិបាល ឬទីភ្នាក់ងារក្រៅរដ្ឋាភិបាល។

លេខទូរស័ព្ទក្នុងសហរដ្ឋអាមេរិក ឬ លេខទូរស័ព្ទសំរាប់រឿងបន្ទាន់ដែលមានខាងក្រោម មានអ្នកទទួលដែលមានការបណ្តុះ-បណ្តាលដើម្បីជួយដល់ជនរងគ្រោះ ២៤ ម៉ោងក្នុងមួយថ្ងៃដោយមិនគិតប្រាក់។ មានអ្នកបកប្រែនិងមានលេខទូរស័ព្ទផ្សេងៗដែលអាចភ្ជាប់អ្នកទៅនឹងសេវាកម្មដោយឥតគិតថ្លៃសំរាប់ជនរងគ្រោះនៅក្នុងតំបន់របស់អ្នក ដែលរួមមានការប្រឹក្សា កន្លែងស្នាក់នៅបន្ទាន់ ការថែទាំផ្នែកសុខភាព ព្រមទាំងយោបល់ផ្នែកច្បាប់។

ប្រសិនបើអ្នកគ្មានថវិការគ្រប់គ្រាន់ក្នុងការចំណាយទៅលើសេវា-កម្មមេធាវី អ្នកអាចមានសិទ្ធិក្នុងការទទួលសេវាកម្មច្បាប់ដោយឥតគិតថ្លៃ ឬក្នុងតំលៃថោកដែលជាជំនួយដល់ជនអន្តោប្រវេសន៍រងគ្រោះដោយសារបទល្មើសផ្សេងៗ ឬអំពើហិង្សាក្នុងគ្រួសារ ។

### ទំនាក់ទំនងអំពីអំពើហិង្សាក្នុងគ្រួសារ

លេខទូរស័ព្ទ: 1-800-799-SAFE (1-800-799-7233)
1-800-787-3224 (TTY)
គេហទំព័រ: www.ndvh.org

### ទំនាក់ទំនងអំពើហិង្សាផ្លូវភេទ ការចាប់រំលោភ ការធ្វើបាប និង ទំនាក់ទំនាក់ផ្លូវភេទរវាងសាច់ញាតិ(RAINN)

លេខទូរស័ព្ទ: 1-800-656-HOPE(1-800-656-4673)
គេហទំព័រ: www.rainn.org

### មជ្ឈមណ្ឌលជាតិទទួលបន្ទុកការបាត់ខ្លួន និងអំពើកេង-ប្រវ័ញ្ចលើកុមារ

លេខទូរស័ព្ទ: 1-800-THE-CALL (1-800-843-5678)
គេហទំព័រ: www.missingkids.com

### មជ្ឈមណ្ឌលជាតិទទួលបន្ទុកជនរងគ្រោះដោយសារបទ-ល្មើស

លេខទូរស័ព្ទ: 1-800-FYI-CALL (1-800-394-2255)
1-800-211-7996 (TTY)

សូមបញ្ជាក់ថា៖ ទាំងនេះគឺជាអង្គការដែលដើរតួនាទីចំបងក្នុងការធានានូវសុវត្ថិភាព និងអោយមានការការពារ។

## តើមានជំរើសក្នុងការធ្វើអន្តោប្រវេសន៍អ្វីខ្លះសំរាប់ខ្ញុំ ប្រសិនបើខ្ញុំជាជនរងគ្រោះអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ និងបទល្មើសផ្សេងៗ?

មានវិធីបីយ៉ាង ដែលជនអន្តោប្រវេសន៍រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ និងបទល្មើសផ្សេងៗ អាចដាក់ពាក្យស្នើសុំការរស់នៅស្របច្បាប់សំរាប់ខ្លួនគេផ្ទាល់ និងកូនៗរបស់ពួកគេ។ ការដាក់ពាក្យសុំរបស់ជនរងគ្រោះនឹងត្រូវបានរក្សាការសម្ងាត់ហើយនឹងគ្មាននរណាម្នាក់ រួមមានអ្នកធ្វើបាបអ្នក ជនប្រព្រឹត្តិល្មើស សមាជិកគ្រួសារ នឹងដឹងអំពីការដាក់ពាក្យស្នើសុំរបស់អ្នកឡើយ។

- ការដាក់ពាក្យធានាខ្លួនឯង ដើម្បីទទួលបានសិទ្ធិស្របច្បាប់ក្រោមច្បាប់ស្តីពីអំពើហិង្សាប្រឆាំងស្ត្រី (VAWA)
- ការស្នើសុំការលុបចោលការបណ្តេញចេញក្រោមច្បាប់ VAWA
- ការស្នើសុំស្ថានភាពមិនមែនអន្តោប្រវេសន៍ “U” (សំរាប់ជនរងគ្រោះដោយសារបទល្មើសផ្សេងៗ) ដើម្បីទទួលបានអត្ថប្រយោជន៍ណាមួយខាងលើ តំរូវអោយអ្នកធ្វើការស្រាយបំភ្លឺបញ្ជាក់ទៅតាមប្រភេទបញ្ហា ដែលលោកអ្នកកំពុងតែប្រឈមមុខ។ សូមប្រឹក្សាជាមួយមេធាវីអន្តោប្រវេសន៍ ដែលធ្វើការជាមួយជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ដើម្បីពិភាក្សាថា តើអត្ថប្រយោជន៍អន្តោប្រវេសន៍មួយណាដែលអាចប៉ះពាល់ដល់អ្នក ឬ ដែលអាចជួយអ្នកបាន។

## តើដំណើរការធ្វើអន្តោប្រវេសន៍តាមរយៈការរៀបការ ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

ដំណើរការក្នុងការធ្វើអន្តោប្រវេសន៍តាមរយៈការរៀបការ ឆ្លងកាត់ដំណាក់កាលមួយចំនួន ក្នុងការទទួលបានសិទ្ធិអន្តោប្រវេសន៍

ស្របច្បាប់នៅសហរដ្ឋអាមេរិក និងចំណាយពេលវេលាដើម្បីអោយមានលក្ខណៈគ្រប់គ្រាន់សំរាប់ចូលសញ្ជាតិ។ ដំណាក់កាលនៃដំណើរការទាំងនេះផ្អែកទៅតាមប្រភេទទិដ្ឋាការរៀបការដែលអ្នកបានសុំ ដើម្បីធ្វើដំណើរទៅរស់នៅសហរដ្ឋអាមេរិក ហើយក៏ស្ថិតទៅលើកត្តាជាក់ស្តែងផ្សេងៗទៀតដែរ។ ព័ត៌មានតទៅនេះនឹងបង្ហាញពីប្រភេទទិដ្ឋាការ និងរួមមានព័ត៌មានផ្សេងៗ ដែលពន្យល់ពីសិទ្ធិស្របច្បាប់របស់អ្នក។

*ប្រភេទទិដ្ឋាការមិនមែនអន្តោប្រវេសន៍* **K-1** (ឬ ជាគូដណ្តឹងរបស់ពលរដ្ឋអាមេរិក)៖ លោកអ្នកតម្រូវអោយរៀបការជាមួយពលរដ្ឋអាមេរិកក្នុងរយៈពេល៩០ថ្ងៃ បន្ទាប់ពីចូលទៅដល់ទឹកដីអាមេរិក បើមិនដូច្នេះទេអ្នកនឹងត្រូវចាកចេញពីសហរដ្ឋអាមេរិកវិញ។ បន្ទាប់ពីបានរៀបការ ជាមួយនឹងគូដណ្តឹងជាពលរដ្ឋអាមេរិកដែលបានដាក់ពាក្យធានាអោយអ្នកហើយ លោកអ្នកត្រូវដាក់ពាក្យសុំសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ ឬ ផ្លាស់ប្តូរលក្ខខ័ណ្ឌរស់នៅ (ពាក្យសុំលេខ I-485)។ នៅពេលដែលពាក្យសុំ I-485 របស់អ្នក ត្រូវបានគេយល់ព្រមលក្ខខ័ណ្ឌរស់នៅរបស់អ្នកនឹងត្រូវបានផ្លាស់ប្តូរពីទិដ្ឋាការមិនមែនអន្តោប្រវេសន៍ K ទៅជាអ្នកមានសិទ្ធិរស់នៅអចិន្ត្រៃយ៍ដែលមានលក្ខខ័ណ្ឌ ហើយលោកអ្នកគឺត្រូវរស់នៅក្នុងលក្ខខ័ណ្ឌនោះរយៈពេល ២ឆ្នាំ។

ប្រសិនបើលោកអ្នកនៅបន្តរស់នៅក្នុងសហរដ្ឋអាមេរិកដោយមិនបានរៀបការជាមួយពលរដ្ឋអាមេរិកដែលជាអ្នកធានាទេ ឬក៏រៀបការជាមួយអ្នកផ្សេង លោកអ្នកនឹងរំលោភទៅលើលក្ខខ័ណ្ឌនៃទិដ្ឋាការរបស់លោកអ្នក ហើយលោកអ្នកនឹងមិនមានសិទ្ធិស្របច្បាប់ក្នុងការរស់នៅក្នុងសហរដ្ឋអាមេរិកទេ និងអាចប្រឈមមុខក្នុងការបញ្ជូនចេញពីសហរដ្ឋអាមេរិក ឬ ទទួលពិន័យផ្សេងៗ។

*ប្រភេទទិដ្ឋាការមិនមែនអន្តោប្រវេសន៍* **K-3** (ជាប្តី / ប្រពន្ធរបស់ពលរដ្ឋអាមេរិក) អ្នកត្រូវបានអនុញ្ញាតិអោយចូលសហរដ្ឋអាមេរិកបណ្តោះអាសន្នដើម្បីរង់ចាំការយល់ព្រមពីការធានាជាប្តី / ប្រពន្ធ (I-130)។ នៅពេលគេអនុម័តលើ I-130 របស់អ្នក ពេលនោះលោកអ្នកត្រូវបានគេផ្តល់សិទ្ធិអោយរស់នៅស្របច្បាប់ (Green Card) ហើយចាំបាច់ត្រូវដាក់ពាក្យសុំ I-485 ដើម្បីស្នើសុំសិទ្ធិរស់នៅអចិន្ត្រៃយ៍ ឬ ផ្លាស់ប្តូរលក្ខខ័ណ្ឌរស់នៅ។

សំរាប់ការធ្វើអន្តោប្រវេសន៍តាមរយៈការរៀបការដទៃផ្សេងទៀត សូមយោងទៅមើលព័ត៌មានដែលផ្តល់អោយពីស្ថានកុងស៊ុល។ ព័ត៌មានបន្ថែមអាចរកបាននៅគេហទំព័រ www.uscis.gov។

**តើមានការផ្តន្ទាទោសអ្វីខ្លះសំរាប់ការរៀបការក្លែងក្លាយ?**

ជនអន្តោប្រវេសន៍ណាដែលបានរៀបការក្លែងក្លាយ អាចប្រឈមមុខក្នុងការបណ្តេញចេញ និងអាចរងការរារាំងក្នុងការទទួលបានប្រយោជន៍ពីការធ្វើអន្តោប្រវេសន៍នានានៅពេលអនាគតនៅក្នុងសហរដ្ឋអាមេរិក។ ការផ្តន្ទាទោសក្នុងការរៀបការក្លែងក្លាយរួមមាន ការដាក់ពន្ធនាគាររហូតដល់ ៥ ឆ្នាំ និងត្រូវពិន័យជាប្រាក់រហូតដល់ ២៥០ ០០០ ដុល្លារ អាមេរិក។

**ប្រសិនបើខ្ញុំបានរៀបការជាមួយពលរដ្ឋអាមេរិកដែលជាអ្នកដាក់ពាក្យធានាខ្ញុំ តើស្ថានភាពអន្តោប្រវេសន៍មានលក្ខណៈដូចម្តេច?**

ប្រសិនបើលោកអ្នកបានរៀបការក្រោមរយៈពេល ២ ឆ្នាំ ហើយនៅពេលដែល I-485 ត្រូវបានគេអនុម័ត លោកអ្នកនឹងទទួលបានសិទ្ធិរស់នៅមានលក្ខខ័ណ្ឌពីការិយាល័យសេវាកម្មសញ្ជាតិ និងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS)។ លោកអ្នក និងប្តី/ប្រពន្ធ ជាទូទៅត្រូវទៅធ្វើការសុំទាំងពីរនាក់ក្នុងរយៈពេល ៩០ថ្ងៃ មុនថ្ងៃគំរប់ឆ្នាំអាពាហ៍ពិពាហ៍លើកទី២ ដើម្បីសុំអោយគេដកចេញលក្ខខ័ណ្ឌលើសិទ្ធិរស់នៅស្របច្បាប់។ ការធ្វើរបៀបនេះគឺត្រូវបង្ហាញភស្តុតាងថាការរៀបការរបស់លោកអ្នកគឺ "ស្មោះត្រង់" និង ត្រឹមត្រូវ។ នៅពេលដែលលក្ខខ័ណ្ឌទាំងនោះត្រូវបានគេដកចេញ លោកអ្នកមានសិទ្ធិរស់នៅក្នុងសហរដ្ឋអាមេរិកជាអចិន្ត្រៃយ៍ដោយមិនចាំបាច់ពឹងផ្អែកលើ ប្តី / ប្រពន្ធសញ្ជាតិអាមេរិករបស់អ្នកទៀតទេ។

ប្រសិនបើលោកអ្នកបានរៀបការលើសពី ២ ឆ្នាំ ហើយនៅពេល I-485 ត្រូវបានគេយល់ព្រម លោកអ្នកនឹងទទួលបានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ពីការិយាល័យសេវាកម្មសញ្ជាតិ និងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS)។ នៅថ្ងៃនោះហើយ ជាពេលដែលលោកអ្នកលែងពឹងផ្អែកលើ ប្តី / ប្រពន្ធជាពលរដ្ឋអាមេរិកសំរាប់ការរស់នៅសហរដ្ឋអាមេរិករបស់អ្នកទៀតហើយ។

សំរាប់អ្នករស់នៅក្នុងលក្ខខ័ណ្ឌ មានស្ថានភាពបីយ៉ាងដែលច្បាប់អនុញ្ញាតអោយអ្នកស្នើសុំសិទ្ធិអនុគ្រោះលើការចាំបាច់ *ដែលតំរូវអោយអ្នក និងប្តី/ប្រពន្ធសញ្ជាតិអាមេរិករបស់អ្នក ត្រូវតែទៅដាក់ពាក្យជាមួយគ្នា ក្នុងការអោយគេដកចេញលក្ខខ័ណ្ឌរស់នៅរបស់អ្នក*។ ទី១ ការបណ្តេញអ្នក (អ្នកដែលរស់នៅអាមេរិកដោយមានលក្ខខ័ណ្ឌ) ចេញពីសហរដ្ឋអាមេរិក នឹងអាចជាហេតុបណ្តាលអោយមានសេចក្តីលំបាកវេទនាខ្លាំងបំផុត។ ឬ ទី២ ការរៀបការរបស់លោកអ្នកត្រូវបានបញ្ចប់ដោយស្របច្បាប់ (មិនមែនដោយភាគីម្ខាងទៀតស្លាប់) ហើយអ្នកដែលជាបេក្ខជនស្នើសុំមិនមានកំហុសក្នុងការមិនបានដាក់ពាក្យសុំនេះតាមពេលវេលាកំណត់។ ឬ ទី៣ កំឡុងពេលរៀបការរបស់អ្នកជាមួយពលរដ្ឋអាមេរិក ឬ ជាមួយអ្នកមានសិទ្ធិរស់នៅស្របច្បាប់ជាអចិន្ត្រៃយ៍នៅអាមេរិក អ្នក (ជនដែលរស់នៅសហរដ្ឋអាមេរិកដោយមានលក្ខខ័ណ្ឌ) បានរងគ្រោះក្នុងការធ្វើបាប ឬ ទទួលរងនូវអំពើអមនុស្សធម៌ផ្សេងៗ។

ការស្នើសុំលើកលែងក្រោមលក្ខខ័ណ្ឌទាំងបីនេះតំរូវអោយបំពេញពាក្យសុំ I-751 ហើយចាំបាច់បង្ហាញភស្តុតាងថាអាពាហ៍ពិពាហ៍របស់លោកអ្នកគឺ "ស្មោះត្រង់" និង មិនក្លែងក្លាយ។

**តើមានមធ្យោបាយណាផ្សេងដែលរដ្ឋាភិបាលអាមេរិកព្យាយាមផ្តល់ព័ត៌មានដល់គូដណ្តឹង ឬ ប្តី / ប្រពន្ធជាជនបរទេសអំពីសិទ្ធិរបស់ពួកគេ និងការការពារពួកគេ និងកូនៗពីអំពើហិង្សា?**

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ IMBRA នៅឆ្នាំ ២០០៥ គឺជាច្បាប់មួយនៅសហរដ្ឋអាមេរិកដែលបានផ្លាស់ប្តូរដំណើរការនៃការជានាជារបៀបគ្រួសារ ដើម្បីជួយដល់គូដណ្តឹង ឬ ប្តី / ប្រពន្ធ ជាជនបរទេស។ ច្បាប់ IMBRA ទាមទារអោយរដ្ឋាភិបាលអាមេរិកផ្តល់ព័ត៌មាន និងឧបករណ៍ជួយខ្លួនឯងដល់គូដណ្តឹង ឬ ប្តី / ប្រពន្ធជាជនបរទេស ដើម្បីការពារខ្លួនអោយរួចផុតពីអំពើហិង្សាដែលកើតឡើងពីភាគីប្តី / ប្រពន្ធដែលបានជានាពួកគេ។ គូដណ្តឹង ឬ ប្តី / ប្រពន្ធជាជនបរទេស ជារឿយៗមិនមានចំណេះដឹង ឬ បទពិសោធន៍ពាក់ព័ន្ធនឹងច្បាប់អាមេរិក ហើយក៏មិនមានការជួយជ្រោមជ្រែងពីក្រុមគ្រួសារ ឬ មិត្តភក្តិណាមួយដើម្បីអោយជៀសផុតពីអំពើហិង្សាដែលកើតឡើងនៅក្នុងផ្ទះពួកគេនោះដែរ។

ច្បាប់ IMBRA បានតំរូវអោយមានការរៀបចំឡើងជាក្រដាសផ្សព្វផ្សាយព័ត៌មាននេះនិងចែកជូនលោកអ្នកអោយដឹងពីច្បាប់និងសេវាកម្មផ្សេងៗដែលអាចជួយលោកអ្នកកំឡុងពេលរស់នៅអាមេរិក ប្រសិនបើលោកអ្នកត្រូវបានគេបំពាន។ ច្បាប់ IMBRA ទប់ស្កាត់ពលរដ្ឋអាមេរិកណា ដែលដាក់ពាក្យធានាទិដ្ឋាការជាច្រើនដង ដល់គូដណ្តឹងច្រើននាក់ ប្រសិនបើពួកគេមានប្រវត្តិពាក់ព័ន្ធបទល្មើសហិង្សា។ IMBRA ស្នើសុំអោយរដ្ឋាភិបាលអាមេរិកចែកជូនដល់លោកអ្នកនូវរបាយការណ៍ប្រវត្តិបទល្មើសរបស់គូដណ្តឹង ឬ ប្តី/ប្រពន្ធជាពលរដ្ឋអាមេរិកដែលរបាយការណ៍នេះចេញដោយការិយាល័យសេវាកម្មសញ្ជាតិ និងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS) ព្រមទាំងភ្ជាប់ជាមួយនូវឯកសារចំលងពាក្យធានាសុំទិដ្ឋាការផងដែរ។

**តើរដ្ឋាភិបាលអាមេរិកដាក់កំរិតដល់ "ភ្នាក់ងារកណ្តាលអន្តរជាតិជួយរកប្តី / ប្រពន្ធ (មេអណ្តើក)" យ៉ាងដូចម្តេច?**

ប្រសិនបើភ្នាក់ងារណាមួយ មានលក្ខណៈសម្បត្តិជា "ភ្នាក់ងារកណ្តាល (មេអណ្តើក) អន្តរជាតិជួយរកប្តី/ ប្រពន្ធ" ពួកគេត្រូវផ្តល់ជូនលោកអ្នកនូវប្រវត្តិរូបរបស់អតិថិជននៅសហរដ្ឋអាមេរិកដែលជាអ្នកចង់ទាក់ទងលោកអ្នក ដែលប្រវត្តិរូបនោះ រួមមានរបាយការណ៍ចេញពីការិយាល័យចុះបញ្ជីប្រវត្តិបទល្មើសផ្លូវភេទរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ហើយភ្នាក់ងារត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីលោកអ្នកសិន មុននឹងផ្តល់ព័ត៌មានទាក់ទងរបស់លោកអ្នកទៅដល់អតិថិជននៅអាមេរិក។ ភ្នាក់ងារកណ្តាល (មេអណ្តើក) ត្រូវផ្តល់ក្រដាសព័ត៌មាននេះមួយច្បាប់ដល់លោកអ្នក។ ប្រសិនបើលោកអ្នកស្ថិតក្រោមអាយុ ១៨ ឆ្នាំ ការផ្គូផ្គងនេះជាការហាមឃាត់។

**តើខ្ញុំអាចជឿជាក់លើរបាយការណ៍ប្រវត្តិបទល្មើសពាក់ព័ន្ធជាមួយគូដណ្តឹង ឬ ប្តី/ប្រពន្ធជាពលរដ្ឋអាមេរិករបស់ខ្ញុំដែរឬទេ?**

របាយការណ៍ប្រវត្តិបទល្មើស គឺបានធ្វើចេញពីប្រភពព័ត៌មានសាធារណៈជាច្រើនព្រមទាំងព័ត៌មានដែលបានផ្តល់អោយដោយអតិថិជនជាពលរដ្ឋអាមេរិកខ្លួនឯងនៅលើពាក្យសុំអន្តោប្រវេសន៍នានា។ ការិយាល័យសេវាកម្មសញ្ជាតិ និងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិកពុំមានសិទ្ធិឆែកមើលបញ្ជីរបាយការណ៍ប្រវត្តិបទល្មើសនៅអាមេរិកទាំងអស់នោះទេ។ អ្នកធានាជាពលរដ្ឋអាមេរិកក៏ប្រហែលជាមិនបានប្រាប់រាល់ព័ត៌មានពិតនៅលើសំនុំឯកសារជានាផងដែរ។ វាអាចទៅរួចដែលថាពលរដ្ឋអាមេរិកមានប្រវត្តិវាយដំ ឬរំលោភបំពាន ប៉ុន្តែពុំធ្លាប់មានការចាប់ខ្លួន ឬ ត្រូវបានផ្តន្ទាទោសនោះដែរ។ ដូច្នេះហើយព័ត៌មានដែលទាក់ទងនឹងប្រវត្តិបទល្មើសដែលលោកអ្នកទទួលបាន អាចពុំមានលក្ខណៈពេញលេញ។ គោលបំណងរបស់ច្បាប់ IMBRA គឺចែកជូនព័ត៌មាននិងប្រភពធនធានដែលមាន ទៅដល់គូដណ្តឹង ឬ ប្តី / ប្រពន្ធដែលនឹងកំពុងធ្វើអន្តោប្រវេសន៍។ ចុងក្រោយលោកអ្នកគឺជាអ្នកទទួលខុសត្រូវក្នុងការសំរេចចិត្តថា តើអ្នកមានអារម្មណ៍ជឿជាក់អំពីទំនាក់-ទំនងរបស់អ្នកដែរឬទេ។

**តើគូដណ្តឹង ឬ ប្តី / ប្រពន្ធជាជនបរទេសដែលជាអ្នករងគ្រោះអំពើហិង្សាក្នុងគ្រួសារ អាចជាជនរងគ្រោះក្នុងការជួញដូរមនុស្សដែរឬអត់?**

រូបភាពផ្សេងទៀតនៃការកេងប្រវ័ញ្ច ដែលរួមបញ្ចូលទាំងការជួញដូរមនុស្ស ពេលខ្លះអាចកើតឡើងស្របពេលព្រមគ្នា ជាមួយអំពើហិង្សាក្នុងគ្រួសារ ពេលដែលការកេងប្រវ័ញ្ចទាក់ទងនឹងការបង្ខិតបង្ខំ ឬក៏រំលោភលើកំលាំងពលកម្ម សេវាកម្មផ្សេងៗ ឬសកម្មភាពជួញដូរផ្លូវភេទ។

**ជំនួយទាក់ទិនការជួញដូរមនុស្សអាចរកបានតាមរយៈ៖**

**មជ្ឈមណ្ឌលព័ត៌មានជាតិស្តីពីការជួញដូរមនុស្ស**
លេខទូរសព្ទ: 1-888-373-7888
(ធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍)
គេហទំព័រ: www.acf.hhs.gov/trafficking

**នាយកដ្ឋានការងារពាក់ព័ន្ធអំពើជួញដូរមនុស្ស និងរំលោភបំពានកម្មករនៃក្រសួងយុត្តិធម៌**

លេខទូរស័ព្ទ: 1-888-428-7581

(ធ្វើការពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ម៉ោង 9 ព្រឹក ដល់ 5 ល្ងាច)

គេហទំព័រ: http://www.usdoj.gov/crt/crim/tpwetf.php

សំរាប់ព័ត៌មានបន្ថែម អាចរកបាននៅក្នុងគេហទំព័រ ឬ តាមរយៈ ការហៅទូរស័ព្ទដោយឥតគិតប្រាក់ ដែលមានដូចខាងក្រោម៖

**ការិយាល័យព័ត៌មានទូទៅរបស់ការិយាល័យសេវាកម្មសញ្ជាតិ និងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS)**

**លេខទូរស័ព្ទ: 1-800-870-3676**

**គេហទំព័រ: http://www.uscis.gov**